# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

សាលាបឋមសិក្សា Laura H. Carnell

1100 West Devereaux Avenue
Philadelphia, PA 19111

ទូរស័ព្ទ៖ (២១៥) ៥៣៧-២៥២៧ ទូរសារ៖ (២១៥) ៥៣៧-៦៣០៥

Hilderbrand Pelzer, នាយិកាសាលា

នេះជាថ្ងៃថ្មីនៅសាលាបឋមសិក្សា Laura H. Carnell

ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២

ជូនចំពោះ៖ មាតាបិតានៃសាលា Laura H. Carnell

ស្តីអំពី៖ **ក្របរក្សាឯកសារថ្ងៃពុធ**

មាតាបិតា៖

សហគមន៍សាលា Laura H. Carnell រីករាយនឹងប្រកាសពីការចាប់ផ្តើមប្រើ ***ក្របរក្សាឯកសារថ្ងៃពុធ។***

ក្នុងគម្រោងការដ៏ទូលំទូលាយរបស់យើងខ្ញុំ យើងបានពន្យល់បញ្ជាក់អំពី ទំនាក់ទំនងជាមួយមាតាបិតា និងការចូលរួមរបស់សហគមន៍ ជាលក្ខណៈសំខាន់មួយ ក្នុងកិច្ចការសំខាន់ៗបីផ្នែករបស់យើង។

ទំនាក់ទំនងគឺជាកត្តាចាំបាច់!

យើងបានបង្កើតវិធីធ្វើទំនាក់ទំនងដែលមានប្រសិទ្ធិភាព និងមានលក្ខណៈល្អបំផុត ជាមួយមាតាបិតារបស់សាលា Carnell ដូចតទៅ៖

- ដំណឹងរបស់សាលា តាមប្រព័ន្ធទូរស័ព្ទស្វ័យប្រវត្តិ
- វ៉ិបសៃរបស់សាលា Laura H. Carnell
- ទំព័រ ហ្វេស ប៊ុក (Face Book) របស់មាតាបិតានៃសាលា Laura H. Carnell
- អ៊ីមែល
- ផ្ញើសារតាមទូរស័ព្ទដៃ

ថ្ងៃនេះ យើងខ្ញុំរីករាយនឹងបន្ថែម ក្របរក្សាឯកសារថ្ងៃពុធ ទៅក្នុងបញ្ជីខាងលើនេះ។

នេះគឺជារបៀបប្រើ ក្របរក្សាឯកសារថ្ងៃពុធ៖

- គ្រូប្រចាំថ្នាក់របស់សិស្សជាអ្នកផ្តល់ ក្របរក្សាឯកសារថ្ងៃពុធ
- រៀងរាល់ថ្ងៃពុធ នៅពេលចប់ម៉ោងរៀន សិស្សយក ក្របរក្សាឯកសារថ្ងៃពុធ ទៅផ្ទះ
- មាតាបិតា អាន និង វិភាគពីឯកសារដែលមាននៅក្នុង ក្របរក្សាឯកសារថ្ងៃពុធ
- មាតាបិតាយកឯកសារដែលមិនត្រូវការចុះហត្ថលេខា**ទាំងអស់**ចេញ
- មាតាបិតាចុះហត្ថលេខាលើទំព័រដែលបានកំណត់ជូន ទទួលដឹងថាគាត់បានអាន និងពិនិត្យអ្វីៗដែលនៅក្នុង ក្របរក្សាឯកសារថ្ងៃពុធ
- មាតាបិតាអាចផ្ញើលិខិតខ្លីៗទៅឲ្យគ្រូ
- មាតាបិតាផ្ញើ ក្របរក្សាឯកសារថ្ងៃពុធ ត្រឡប់មកវិញនៅព្រឹកថ្ងៃព្រហស្បត៍

យើងខ្ញុំរង់ចាំការទាក់ទងគ្នាយ៉ាងជាប់លាប់ និងល្អៗ តាមការប្រើវិធី**ទាំងអស់**ខាងលើ ដើម្បីផ្តល់ **ការអប់រំដែលមានលក្ខណៈសកល** ដល់សិស្សានុសិស្សនៅសាលា Carnell **ទាំងអស់**។

សាមគ្គីភាព

ក្រុមគ្រូសារសាលា Carnell

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer